# សិក្ខាសាលាផ្សព្វផ្សាយលទ្ធផលនៃសន្និសីទលើកទី ១៩
# នៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ

## ទិដ្ឋភាពរួមនៃសន្និសីទលើកទី ១៩ នៃអនុសញ្ញា UNFCCC

សណ្ឋាគារ ហ៊ីម៉ាវ៉ារី ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១៣

**ទិន ពន្លក**
អគ្គនាយករង, GDANCP
ក្រសួងបរិស្ថាន

# មាតិកា

- សារតានៃ **UNFCCC/CoP**
- ចំណុចគោល/ សមិទ្ធផលសំខាន់ៗ
- កិច្ចការសំខាន់ៗសម្រាប់ **CoP-19**
- ជំហរកម្ពុជា
- សកម្មភាពរបស់ប្រតិភូកម្ពុជា

- សាវតានៃ **UNFCCC/CoP**
- ចំណុចគោល/ សមិទ្ធផលសំខាន់ៗ
- កិច្ចការសំខាន់ៗសម្រាប់ **CoP-19**
- ជំហរកម្ពុជា
- សកម្មភាពរបស់ប្រតិភូកម្ពុជា

# និម្មាបនកម្មនៃគោលនយោបាយប្រែប្រួលអាកាសធាតុ



# អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC)

- ក្របខ័ណ្ឌគោលនយោបាយពិភពលោកសម្រាប់ដោះស្រាយការប្រែប្រួលអាកាសធាតុ
- ផ្តោតលើការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ និងការឆ្លើយតបនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ
- ផ្អែកលើគោលការណ៍នៃការទទួលខុសត្រូវរួម ប៉ុន្តែក្នុងកម្រិតដោយឡែកពីគ្នា (ខុសគ្នារវាងប្រទេសជឿនលឿន និងប្រទេសកំពុងអភិវឌ្ឍន៍) ការអភិវឌ្ឍដោយចីរភាព។ល។
- បានចុះហត្ថលេខានៅឆ្នាំ ១៩៩២ ក្នុងទីក្រុងរីយ៉ូ
- បានចូលជាធរមាននៅឆ្នាំ ១៩៩៤
- ប្រទេសចំនួន ១៩៥ ជាភាគីសមាជិក

# គោលបំណងនៃ UNFCCC ( មាត្រា ២ )

គោលដៅចុងក្រោយ... គឺ

**សម្រេចបាន... ស្ថិរភាពនៃកំហាប់ឧស្ម័នផ្ទះកញ្ចក់** នៅក្នុងបរិយាកាស ក្នុងកម្រិតដែលអាចទប់ស្កាត់**ការរំខានប្រកបដោយគ្រោះថ្នាក់ពីសកម្មភាពមនុស្ស**មកលើប្រព័ន្ធអាកាសធាតុ។ កម្រិតបែបនេះគួរតែអាចសម្រេចបាននៅក្នុងពេលវេលាគ្រប់គ្រាន់ដើម្បី**អាចឲ្យប្រព័ន្ធអេកូឡូស៊ីបន្សាំ**តាមធម្មជាតិទៅនឹងការប្រែប្រួលអាកាសធាតុ ដើម្បីធានាថា **ផលិតកម្មស្បៀងមិនរងការគំរាមកំហែង** និង**អាចឲ្យការអភិវឌ្ឍសេដ្ឋកិច្ចប្រព្រឹត្តទៅដោយចីរភាព**។

# អង្គភាពនានានៃ UNFCCC

- COP – សន្និសីទភាគីនៅក្នុង UNFCCC
- CMP (ដែលមានសរសេរបែបនេះផងដែរ COP/MOP) – សន្និសីទភាគីនៅក្រោម UNFCCC ដែលមាននាទីជាកិច្ចប្រជុំនៃភាគីនៅក្រោមពិធីសារក្យូតូ
- SBI – អង្គភាពទទួលបន្ទុកកិច្ចការអនុវត្ត
- SBSTA – អង្គភាពទទួលបន្ទុកផ្តល់យោបល់វិទ្យាសាស្ត្រ និងបច្ចេកទេស
- ក្រុមអ្នកជំនាញការ – ក្រុមអ្នកជំនាញការខាងការផ្ទេរបច្ចេកវិទ្យា (EGTT), ក្រុមអ្នកជំនាញការខាងប្រទេសអភិវឌ្ឍន៍តិចតួច (LEG)
- AWG-LCA, KP, DP – ក្រុមការងារ*ពិសេស* ខាងសកម្មភាពសហប្រតិបត្តិការរយៈពេលវែង, ពិធីសារក្យូតូ, និងវេទិកាឌូបិន

# ភ្នាក់ងារចំបងៗ

## ភ្នាក់ងារចំបងៗនៅក្នុងការចរចា

- **ប្រទេសជឿនលឿន**
  - សហភាពអឺរ៉ុប
  - ស.រ.អា
  - ភ្នាក់ងារដទៃទៀតនៅក្នុងក្រុមខុសៗគ្នា (ក្រោមក្របខ័ណ្ឌ, ។ល។)
- **ប្រទេសកំពុងអភិវឌ្ឍន៍ (G-77+ចិន)**
  - រដ្ឋកំពុងអភិវឌ្ឍន៍លើកោះតូចៗ (AOSIS)
  - ក្រុមប្រទេសអភិវឌ្ឍន៍តិចតួច (LDC)
  - ក្រុមថ្នាក់តំបន់ (អាហ្វ្រិក អាមេរិកឡាទីន ។ល។)
  - អូប៉ិច (OPEC)
- **ភ្នាក់ងារមិនមែនរដ្ឋ**
  - NGOs (ក្រុមយុទ្ធនាការបៃតង, ក្រុមសមធម៌និងយុត្តិធម៌, ។ល។)
  - ក្រុមដែលមានចំណាប់អារម្មណ៍ដទៃទៀត (ដូចជា ក្រុមប្រឆាំងការប្រែប្រួលអាកាសធាតុ)
  - ទីភ្នាក់ងារពហុភាគី និងវិទ្យាស្ថានហិរញ្ញវត្ថុ (GEF, UN, ធនាគារពិភពលោក។ល។)

# មូលនិធិ

- ប្រទេសជឿនលឿនជាប់ការប្ដេជ្ញាគាំទ្រដល់ប្រទេសកំពុងអភិវឌ្ឍន៍ក្នុងសកម្មភាពមួយចំនួន ដែលរួមទាំង៖
  - ការកសាងសមត្ថភាព
  - ការផ្ទេរបច្ចេកវិទ្យា
  - ការអប់រំ ការបណ្ដុះបណ្ដាល និងការយល់ដឹងសាធារណៈ
  - ការបន្ស៊ាំ
  - ការធ្វើរបាយការណ៍
- មូលនិធិបរិស្ថានពិភពលោកគឺជា"អង្គភាពដែលប្រតិបត្តិការជាយន្តការហិរញ្ញវត្ថុ" (មិនមែនជាមូលនិធិបន្ស៊ាំទេឡើយ)

- សាវតានៃ UNFCCC/CoP
- ចំណុចគោល/ សមិទ្ធផលសំខាន់ៗ
- កិច្ចការសំខាន់ៗសម្រាប់ CoP-19
- ជំហរកម្ពុជា
- សកម្មភាពរបស់ប្រតិភូកម្ពុជា

# ចំណុចគោលសំខាន់ៗ (1)

- ១៩៩២ — UNFCCC ត្រូវបានបើកចំហសម្រាប់ការចុះហត្ថលេខានៅកិច្ចប្រជុំកំពូលផែនដីនៅក្រុងរីយ៉ូ
- ១៩៩៤ — UNFCCC ចូលជាធរមាន
- ១៩៩៥ — សន្និសីទភាគីលើកដំបូង (COP-1)នៅក្រុងប៊ែរឡាំង
- ១៩៩៧ — ពិធីសារក្យូតូត្រូវបានអនុម័តជាផ្លូវការនៅខែធ្នូក្នុងCOP-3
- ២០០៥ — ការចូលជាធរមាននៃពិធីសារក្យូតូ។ កិច្ចប្រជុំដំបូងនៃភាគីក្នុងពិធីសារក្យូតូ (MOP 1) ធ្វើឡើងនៅក្រុងម៉ុងរ៉េអាល់
- ២០០៧ — ការចេញផ្សាយរបាយការណ៍វាយតម្លៃលើកទី ៤របស់ IPCC។ នៅ COP13 ភាគីនានាបានឯកភាពលើផែនទីបង្ហាញផ្លូវក្រុងបាលី។

# ចំណុចគោលសំខាន់ៗ (2)

- ២០០៩ – កិច្ចព្រមព្រៀង(Accord) កូប៉េនហាក បានរៀបចំជាសេចក្តីព្រាងនៅក្នុងCOP-15 នៅទីក្រុងកូប៉េនហាក។ COP បានកត់សំគាល់ពីដំណើរការនេះ។ ក្រោយមកប្រទេសនានាបានដាក់ជូនការសន្យាកាត់បន្ថយការបំភាយ ឬ ការសន្យាអំពីសកម្មភាពកាត់បន្ថយរបស់ខ្លួន ដែលទាំងអស់នេះឥតជាប់កាតព្វកិច្ចឡើយ
- ២០១០– កិច្ចព្រមព្រៀងកាន់គុន ត្រូវបានរៀបចំជាសេចក្តីព្រាង និងបានទទួលយកភាគច្រើននៅក្នុង COP-16
- ២០១១ – វេទិកាឌូបិនសម្រាប់ពង្រឹងសកម្មភាពត្រូវបានរៀបចំជាសេចក្តីព្រាង និងទទួលយកនៅក្នុងCOP-17.
- ២០១២ - វិសោធនកម្មដូហា នៅក្រោមពិធីសារក្យូតូត្រូវបានអនុម័តដោយ CMP នៅក្នុង CMP8

- សារតានៃ **UNFCCC/CoP**
- ចំណុចគោល/ សមិទ្ធផលសំខាន់ៗ
- **កិច្ចការសំខាន់ៗសម្រាប់ CoP-19**
- ជំហរកម្ពុជា
- សកម្មភាពរបស់ប្រតិភូកម្ពុជា

# កិច្ចប្រជុំនានានៅវ៉ាសូវី

- សម័យប្រជុំលើកទី ១៩ នៃសន្និសីទភាគី (COP-19)
- សម័យប្រជុំលើកទី៩ នៃភាគីដែលមាននាទីជាកិច្ចប្រជុំនៃភាគីក្នុងពិធីសារក្យូតូ(CMP 9)
- សម័យប្រជុំលើកទី ៣៩ នៃអង្គភាពអនុវត្ត (SBI 39)
- សម័យប្រជុំលើកទី ៣៩ នៃអង្គភាពផ្តល់យោបល់វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (SBSTA 39)
- សម័យប្រជុំលើកទី ២ នៃក្រុមការងារពិសេសស្តីពីវេទិកាឌូបិន សម្រាប់ពង្រឹងសកម្មភាព (ផ្នែកទី ៣) (ADP 2.3)

# កិច្ចការសំខាន់ៗសម្រាប់ CoP-19

- ការកាត់បន្ថយ៖ NAMAs, ការផ្តល់សច្ចាប័នលើ KP2, ចំណុចនានាដែលត្រូវបញ្ចូលនៅក្នុងសេចក្តីព្រាងអត្ថបទនៃកិច្ចព្រមព្រៀងថ្មី
- ការបន្សាំ៖ គាំទ្រ NAPAs និង NAPs ក្នុងប្រទេសកំពុងអភិវឌ្ឍន៍
- ហិរញ្ញវត្ថុ៖ ការប្តេជ្ញាខាងហិរញ្ញវត្ថុសម្រាប់ ២០១៣-២០២០, ជម្រុញ មូលនិធិអាកាសធាតុបៃតងឲ្យមានដំណើរការ, ផែនទីបង្ហាញផ្លូវដើម្បីកៀងគរ ១00ពាន់លានដុល្លា/ឆ្នាំ រហូតដល់ឆ្នាំ ២០២០
- បច្ចេកវិទ្យា៖ ការផ្ទេរបច្ចេកវិទ្យាដល់ប្រទេសកំពុងអភិវឌ្ឍន៍
- ការបាត់បង់និងការខូចខាត៖ យន្តការដើម្បីគាំទ្រដល់ការបាត់បង់និងការខូចខាត
- REDD+: កម្រិតយោង, MRV

# មាតិកា

- សាវតានៃ UNFCCC/CoP
- ចំណុចគោល/ សមិទ្ធផលសំខាន់ៗ
- កិច្ចការសំខាន់ៗសម្រាប់ CoP-19
- ជំហរកម្ពុជា
- សកម្មភាពរបស់ប្រតិភូកម្ពុជា

# ជំហររបស់កម្ពុជា (1)

- គាំទ្រដល់កិច្ចប្រឹងប្រែងដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុ ដោយផ្អែកលើគោលការណ៍UNFCCC និងការភ្ជាប់ខ្លួនជាមួយ LDCs និង G77+ ចិន
- ភាគីក្នុងឧបសម្ព័ន្ធ ១ ត្រូវនាំមុខក្នុងការកាត់បន្ថយ GHG, ភាគីមិននៅក្នុងឧបសម្ព័ន្ធ ១ អាចចូលរួមដោយស្ម័គ្រចិត្ត (ដែលរួមទាំងតាមរយៈ NAMAs)
- គាំទ្រដល់ NAPs ក្នុងប្រទេសកំពុងអភិវឌ្ឍន៍ និងកម្មវិធីការងារស្តីពីការបាត់បង់ និងការខូចខាត ដោយផ្អែកលើអាទិភាពនៃប្រទេសនីមួយៗ
- គាំទ្រដល់អំឡុងពេលនៃការប្តេជ្ញាលើកទីពីរក្រោមពិធីសារក្យូតូ

# ជំហររបស់កម្ពុជា (2)

- អំពាវនាវឲ្យមានការឯកភាពលើវិធីសាស្រ្ត និងគំរូសម្រាប់អនុវត្ត REDD+
- គាំទ្រដល់ការផ្តល់ហិរញ្ញវត្ថុដែលអាចព្យាករណ៍បាន បន្ថែម និងថ្មី ពីប្រភពសាធារណៈ ពីសំណាក់ប្រទេសក្នុងឧបសម្ព័ន្ធ ១
- លើកទឹកចិត្តប្រទេសជឿនលឿនឲ្យផ្តល់១00ពាន់លានដុល្លាអាមេរិក/ឆ្នាំ ដល់ប្រទេសកំពុងអភិវឌ្ឍន៍ រហូតដល់ឆ្នាំ២០២០។ អំពាវនាវឲ្យមានផែនទីបង្ហាញផ្លូវហិរញ្ញវត្ថុពិស្តារ ដើម្បីផ្តល់ហិរញ្ញវត្ថុថ្មី អាចព្យាករណ៍បាន និងបន្ថែម ពីប្រភពសាធារណៈដល់ប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីបំពេញភាគខ្វះខាតរវាងឆ្នាំ ២០១៣-២០២០
- គាំទ្រឲ្យមានការពង្រឹងសកម្មភាពដើម្បីលើកកំពស់សមត្ថភាព និងលទ្ធភាពរបស់ប្រទេសកំពុងអភិវឌ្ឍន៍។ ការកសាងសមត្ថភាពគួរតែជាដំណើរការជាប់ជាបន្ត នាំមុខដោយប្រទេសម្ចាស់ផ្ទះ និងតាមបែបផែននៃការចូលរួមពេញលេញ និងដំណើរការចម្រុះ។

# មាតិកា

- សាវតានៃ **UNFCCC/CoP**
- ចំណុចគោល/ សមិទ្ធផលសំខាន់ៗ
- កិច្ចការសំខាន់ៗសម្រាប់ **CoP-19**
- ជំហរកម្ពុជា
- សកម្មភាពរបស់ប្រតិភូកម្ពុជា

# សកម្មភាពរបស់ប្រតិភូកម្ពុជា (1)

- ប្រតិភូមួយក្រុមមានសមាសភាព ១៦នាក់ (៣នាក់ពី MAFF) ដឹកនាំដោយឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន (នៅក្នុងអំឡុងពេលសម័យប្រជុំជាន់ខ្ពស់)
- បានចូលរួមក្នុងកិច្ចប្រជុំនានា ដោយផ្អែកតាមវិស័យនៃការទទួលខុសត្រូវ
- សកម្មភាពរបស់ឯកឧត្តមរដ្ឋមន្ត្រី (ថ្ងៃទី ១៩-២១ ខែវិច្ឆិកា)
  - ព្រឹត្តិការណ៍ជាន់ខ្ពស់ស្របគ្នានៅក្នុង COP 19 (ការចូលរួមនៃអគ្គលេខាធិការនៃអ.ស.ប)
  - ការចូលរួមនៅក្នុងពិធីបើកសម័យប្រជុំជាន់ខ្ពស់
  - កិច្ចប្រជុំជាមួយរដ្ឋមន្ត្រីបរិស្ថានជប៉ុន អ៊ីស៊ីហារ៉ា
  - ការជួបពិសារអាហារល្ងាចជាផ្លូវការសម្រាប់ប្រតិភូ/រដ្ឋមន្ត្រី
  - ការសន្ទនាជាន់ខ្ពស់ថ្នាក់រដ្ឋមន្ត្រីស្តីពីវេទិកាឧបិនសម្រាប់ពង្រឹងសកម្មភាព
  - ការជួបពិសារអាហារល្ងាចជាផ្លូវការជាមួយប្រតិភូឥណ្ឌូនេស៊ី
  - ការអានសេចក្តីថ្លែងការណ៍របស់កម្ពុជាដោយឯកឧត្តមរដ្ឋមន្ត្រី

# សកម្មភាពរបស់ប្រតិភូកម្ពុជា (2)

- ក្រុមប្រឹក្សាប្រតិបត្តិនៃ UN CDM បានអនុម័តសំណើ DNA កម្ពុជាស្តីពីស្តង់ដារលក្ខខណ្ឌគោល "ការប្តូរបច្ចេកវិទ្យាក្នុងវិស័យកិនស្រូវនៅកម្ពុជា" នៅក្នុងកិច្ចប្រជុំលើកទី ៧៦ ដែលបានធ្វើឡើងពីថ្ងៃទី ៤ ដល់ ៨ ខែវិច្ឆិកា
- បានធ្វើបទបង្ហាញស្តីពីបទពិសោធន៍របស់ CCCA នៅក្នុងពិធីស្របពេលគ្នាមួយរបស់ EU ""ផ្តើមចេញពីយុទ្ធសាស្ត្រអាកាសធាតុចម្រុះ ទៅកាន់ប្រសិទ្ធិភាពហិរញ្ញវត្ថុអាកាសធាតុ៖ តួនាទីនៃការបញ្ជ្រាប និងការពង្រឹងស្ថាប័ន"
- បានធ្វើបទបង្ហាញមួយស្តីពីមេរៀនទទួលបានពីបទពិសោធន៍ជាក់ស្តែងក្នុងប្រទេសស្តីពី សកម្មភាពកាត់បន្ថយដែលសមស្របនៅថ្នាក់ជាតិ (NAMAs) ក្រុងប្រទេសកម្ពុជានៅក្នុងពិធីស្របពេលគ្នាមួយ ដែលចាត់ចែងឡើងដោយក្រសួងបរិស្ថានជប៉ុន


ERITREA
EQUATORIAL GUINEA
CAMBODIA
CABO V


UNITED NATIONS
CLIMATE CHANGE CONFERENCE
COP19/CMP9
WARSAW 2013




Elisabeth Holland
Dr Pendo Maro
Tin Ponlock


Giza Caspar Martins
DNA Forum Co-Chair
Malin Ahlberg





# ការអនុម័តដោយនាយករដ្ឋមន្ត្រីលើសំណើរបស់ MoE នៅក្រោយCoP-18

១. សុំរាជរដ្ឋាភិបាលមេត្តាពិនិត្យលទ្ធភាពផ្តល់សច្ចាប័នលើវិសោធនកម្មទីក្រុងដូហានៃពិធីសារក្យូតូ ដើម្បីអាចឱ្យកម្ពុជាបន្តចូលរួមអនុវត្តបណ្តាគម្រោងយន្តការអភិវឌ្ឍន៍ស្អាត នៅក្នុងដំណាក់កាលកាតព្វកិច្ចលើកទី២ នៃការអនុវត្តពិធីសារក្យូតូ ឆ្នាំ ២០១២-២០២០

២. សុំការអនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជា ក្នុងការចាត់តាំងក្រសួងបរិស្ថានជាអង្គភាពថ្នាក់ជាតិសម្រាប់សម្របសម្រួលការងារ REDD+ ហើយជូនដំណឹងជាផ្លូវការទៅលេខាធិការដ្ឋាននៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ

៣. សុំការអនុញ្ញាតជាគោលការណ៍ពីរាជរដ្ឋាភិបាលកម្ពុជា ដើម្បីឱ្យក្រសួងបរិស្ថានសហការជាមួយឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ដើម្បីពិនិត្យសិក្សាសំណើរបស់ភាគីជប៉ុនស្តីពីការអនុវត្តយន្តការឥណទានកាបូនរួមគ្នា (Joint Crediting Mechanism: JCM) មុននឹងចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ។ ការអនុវត្តយន្តការឥណទានកាបូនរួមគ្នានេះ អាចរួមចំណែកកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ជាពិសេសអាចឱ្យកម្ពុជាទទួលបាននូវការគាំទ្រផ្នែកហិរញ្ញវត្ថុ និងការផ្ទេរបច្ចេកវិទ្យាទំនើបពីប្រទេសជប៉ុន។

# ការអនុម័តដោយនាយករដ្ឋមន្ត្រីលើសំណើរបស់ MoE នៅក្រោយCoP-18

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខ: ៧០២៦ សជណ.ករ

ក្រសួងបរិស្ថាន
លេខ: ៣១៧៣
ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ២០១៣
ម៉ោង: ១០:០០

ភ្នំពេញ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០១៣

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**សូមជម្រាបជូន**
**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**កម្មវត្ថុ** : របាយការណ៍ស្តីពីលទ្ធផលសន្និសីទលើកទី១៩ នៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ នៅទីក្រុងវ៉ារស្សាវ៉ា ប្រទេសប៉ូឡូញ ចាប់ពីថ្ងៃទី១១ ដល់ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៣។

**យោង** : -លិខិតលេខ ៦៥១ ក្រប.ស្គ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៣ របស់ក្រសួងបរិស្ថាន
- ចំណារសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៣។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រី សូមជម្រាបជូនឯកឧត្តមរដ្ឋមន្ត្រីជ្រាបថា ការដាក់ជូនពិចារណាខាងលើ និងឯកភាពលើរបាយការណ៍របស់ក្រសួងបរិស្ថាន ដូចខាងក្រោម៖

១. ពិនិត្យលទ្ធភាពផ្តល់សច្ចាប័នលើវិសោធនកម្មទីក្រុងដូហានៃពិធីសារក្យូតូ ដើម្បីអាចឲ្យកម្ពុជាបន្តចូលរួមអនុវត្តបណ្តាគម្រោងយន្តការអភិវឌ្ឍន៍ស្អាត នៅក្នុងដំណាក់កាលកាតព្វកិច្ចលើកទី២ នៃការអនុវត្តពិធីសារក្យូតូ ឆ្នាំ២០១២-២០២០។

២. ចាត់តាំងក្រសួងបរិស្ថានជាអង្គភាពថ្នាក់ជាតិសម្រាប់សម្របសម្រួលការងារ REDD+ ហើយជូនដំណឹងជាផ្លូវការទៅលេខាធិការដ្ឋាននៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ។

៣. អនុញ្ញាតជាគោលការណ៍ជូនក្រសួងបរិស្ថានសហការជាមួយឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ដើម្បីពិនិត្យសិក្សាសំណើរបស់ភាគីជប៉ុន ស្តីពីការអនុវត្តយន្តការផ្តល់ឥណទានកាបូនរួមគ្នា (Joint Crediting Mechanism: JCM) មុននឹងចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមរដ្ឋមន្ត្រីជ្រាប និងចាត់ចែងអនុវត្តតាមការគួរ។

ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
រដ្ឋលេខាធិការ

គឹមរ៉ែន សំរេច

**បញ្ជូនជូន:**
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រី សុខ អាន
-ឯកសារ-កាលប្បវត្តិ

# សូមអរគុណ!